Mekong River Commission Secretariat
P.O. Box 6101, 184 Fa Ngoum Road, Unit 18,
Ban Sithane Neua, Sikhottabong District, Vientiane 01000, Lao PDR
Telephone: (856-21) 263 263 Facsimile: (856-21) 263 264

# ព័ត៌មានសង្ខេប អំពីគណៈកម្មការទន្លេមេគង្គ

## តើយើងជាអ្នកណា

គណៈកម្មការទន្លេមេគង្គ (MRC) គឺជាស្ថាប័នអន្តររដ្ឋាភិបាល ដែលបំពេញការងារដើម្បីជួយសម្រួលដល់កិច្ចសហប្រតិបត្តិការជុំវិញការអភិវឌ្ឍ និងគ្រប់គ្រងតំបន់អាងទន្លេមេគង្គ ប្រកបដោយចីរភាព។ សមាជិករបស់គណៈកម្មការនេះ រួមមាន ប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។

គណៈកម្មការទន្លេមេគង្គបំពេញតួនាទី ជាវេទិកាសម្រាប់ការទូតផ្នែកទឹក និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ ដែលតាមរយៈវេទិកានេះ ប្រទេសជាសមាជិកធ្វើការចែករំលែកអត្ថប្រយោជន៍ ដែលបានពីធនធានទឹករួម និងឆ្លើយតបចំពោះបញ្ហាប្រឈមឆ្លងដែននៅក្នុងតំបន់អាងទន្លេនេះ បើទោះបីជាប្រទេសសមាជិកទាំងនេះ មានផលប្រយោជន៍ជាតិខុសគ្នាយ៉ាងណាក៏ដោយ។ គណៈកម្មការនេះ ក៏បំពេញតួនាទីជាមជ្ឈមណ្ឌលចំណេះដឹង សម្រាប់ជម្រុញឱ្យមានការតាក់តែងគោលនយោបាយ ផ្អែកតាមភស្តុតាងជាក់ស្តែងផងដែរ។ គណៈកម្មការនេះ ផ្តល់ជំនួយបច្ចេកទេស និងបង្កើតជាឧបករណ៍ដើម្បីជួយឱ្យប្រទេសជាសមាជិកធ្វើការសម្រេចចិត្តផ្អែកតាមព័ត៌មានត្រឹមត្រូវ។

គណៈកម្មការទន្លេមេគង្គ ត្រូវបានបង្កើតឡើង នៅពេលដែលប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាមចុះហត្ថលេខាលើ កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៃតំបន់អាងទន្លេមេគង្គ ដែលហៅកាត់ថា កិច្ចព្រមព្រៀងមេគង្គ កាលពីថ្ងៃទី ៥ ខែ មេសា ឆ្នាំ ១៩៩៥ (1995 Mekong Agreement) ។ ប្រទេសជាសមាជិកបានឯកភាពសហការណ៍ជាមួយគ្នាលើវិស័យជាច្រើន ដូចជា វិស័យនេសាទ ការគ្រប់គ្រងទឹកជំនន់ ធារាសាស្ត្រ វារីអគ្គិសនី និងនាវាចរណ៍។ ប្រទេសចិន និងមីយ៉ាន់ម៉ា ដែលស្ថិតនៅផ្នែកខាងលើបង្អស់នៃលំហូរទន្លេមេគង្គ គឺជាដៃគូសន្ទនារបស់ MRC ចាប់ពីតាំងពីឆ្នាំ ១៩៩៦ មក។

## រចនាសម្ព័ន្ធ និងអភិបាលកិច្ចរបស់យើង

គណៈកម្មការទន្លេមេគង្គ សម្របសម្រួលកិច្ចពិគ្រោះយោបល់ និងការចរចាស្តីពីការគ្រប់គ្រងធនធានទឹក រវាងរដ្ឋាភិបាល វិស័យឯកជន សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធដទៃទៀត។ គណៈកម្មការនេះបំពេញតួនាទីយ៉ាងសកម្ម ក្នុងនាមជាអ្នកសម្របសម្រួលអព្យាក្រឹត្យ ដើម្បីធ្វើឱ្យមានតុល្យភាពរវាងផល

ប្រយោជន៍របស់ជាតិនិងផលប្រយោជន៍សម្រាប់អាងទន្លេទាំងមូល តុល្យភាពរវាងប្រទេសមួយ និងប្រទេសមួយទៀត និងតុល្យភាពរវាងតម្រូវការនៃការអភិវឌ្ឍ និងនិរន្តរភាពបរិស្ថាន។

លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ (MRC Secretariat) មានការិយាល័យកណ្តាលក្នុងទីក្រុងវៀងចន្ទ ប្រទេសឡាវ ខណៈពេលដែលមជ្ឈមណ្ឌលគ្រប់គ្រង និងកាត់បន្ថយទឹកជំនន់ថ្នាក់តំបន់ (RFMMC) មានទីតាំងស្ថិតក្នុងទីក្រុងភ្នំពេញ។ លេខាធិការដ្ឋានរបស់គណៈកម្មការនេះទទួលខុសត្រូវលើការងារប្រតិបត្តិការប្រចាំថ្ងៃ របស់គណៈកម្មការ និងមានបុគ្គលិកជំនាញ និងបុគ្គលិកគាំទ្រជាង ៦០ នាក់។ លេខាធិការដ្ឋានត្រូវរាយការណ៍ទៅកាន់គណៈកម្មាធិការចម្រុះនៃគណៈកម្មការទន្លេមេគង្គ (Joint Committee) ដែលជាស្ថាប័នគ្រប់គ្រងសំខាន់ជាងគេរបស់គណៈកម្មការទន្លេមេគង្គនេះ។

គណៈកម្មាធិការចម្រុះនៃគណៈកម្មការទន្លេមេគង្គ ដាក់ចេញទិសដៅ និងអាទិភាពជុំវិញកិច្ចសហប្រតិបត្តិការជាមួយនឹងគណៈកម្មាធិការជាតិទន្លេមេគង្គនៃប្រទេសជាសមាជិក (National Mekong Committees) និងធ្វើការពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានារបស់គណៈកម្មការទន្លេមេគង្គ។ ក្រុមប្រឹក្សារបស់គណៈកម្មការទន្លេមេគង្គ (MRC Council) គឺជាស្ថាប័នធ្វើការសម្រេចចិត្តកម្រិតខ្ពស់បំផុតក្នុងគណៈកម្មការទន្លេមេគង្គ។ ក្រុមប្រឹក្សានេះធ្វើការសម្រេចចិត្តអំពីបញ្ហាគោលនយោបាយទាំងអស់ ពាក់ព័ន្ធនឹងការអនុវត្ត ដូចជា គោលនយោបាយរបស់ស្ថាប័ន យុទ្ធសាស្ត្រនិងផែនការរបស់តំបន់អាងទន្លេទាំងមូល ភាពជាដៃគូសហប្រតិបត្តិការជាយុទ្ធសាស្ត្រ និងការដោះស្រាយចំណុចខ្វែងគំនិតគ្នាជាដើម។

គណៈកម្មការទន្លេមេគង្គទទួលបានថវិកាគាំទ្រពីប្រទេសជាសមាជិក និងដៃគូអភិវឌ្ឍន៍របស់ខ្លួន ដូចជា ប្រទេសអូស្ត្រាលី បែលហ្ស៊ិក សហភាពអឺរ៉ុប ហ្វាំងឡង់ បារាំង អាល្លឺម៉ង់ ជប៉ុន លុចហ្សំបួរ ហូឡង់ ស៊ុយអ៊ែត ស្វីស សហរដ្ឋអាមេរិក និងធនាគារពិភពលោក ដែលសុទ្ធជាដៃគូអភិវឌ្ឍន៍ នាពេលបច្ចុប្បន្នរបស់គណៈកម្មការនេះ។ ថវិកាប៉ាន់ប្រមាណ សម្រាប់រយៈពេលនៃផែនការយុទ្ធសាស្ត្រពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២០ គឺ ៦៥ លានដុល្លារ ថយចុះ ៣៥% បើធៀបនឹងរយៈពលមុន (២០១០-២០១៥)។ នេះឆ្លុះបញ្ចាំងពីការបន្តអនុវត្តដំណើរការវិមជ្ឈការរបស់គណៈកម្មការទន្លេមេគង្គ ដែលគេរំពឹងថា នឹងធ្វើឱ្យស្ថាប័នអាចជានាបាននូវនិរន្តរភាពពេញលេញដោយខ្លួនឯងត្រឹមឆ្នាំ ២០៣០ តាមរយៈការផ្តល់ថវិកាគាំទ្រពីប្រទេសជាសមាជិក។

## ការងាររបស់យើង

កិច្ចព្រមព្រៀងទន្លេមេគង្គ គឺជាមូលដ្ឋានសម្រាប់ឱ្យគណៈកម្មការទន្លេមេគង្គផ្តល់ការគាំទ្រដល់ដំណើរការរៀបចំផែនការក្នុងតំបន់អាងទន្លេទាំងមូល ដោយប្រើប្រាស់គោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះ។ គណៈកម្មការនេះ ធ្វើការងារផ្តោតលើគ្រប់វិស័យទាំងអស់ ដើម្បីឈានទៅសម្រេចគោលបំណងចម្រុះ ដូចជា ការធានានូវនិរន្តរភាពធនធាននេសាទ ការជំរុញលើកម្ពស់វារីអគ្គិសនីប្រកបដោយចីរភាព ការកំណត់រកឱកាសសម្រាប់ធារាសាស្ត្រកសិកម្ម ការរក្សាសេរីភាពនៃការធ្វើនាវាចរណ៍ ការកែលម្អការគ្រប់គ្រងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត និងការរក្សាការពារប្រព័ន្ធអេកូឡូហ្ស៊ីសំខាន់ៗ។ គោលដៅចម្បងរបស់គណៈកម្មការនេះ គឺលើកកម្ពស់ និងសម្របសម្រួលការអភិវឌ្ឍ និងការគ្រប់គ្រងធនធានទឹក និងធនធានដែលពាក់ព័ន្ធ នៃតំបន់អាងទន្លេមេគង្គប្រកបដោយចីរភាព ដើម្បីអត្ថប្រយោជន៍ទៅវិញទៅមករបស់ប្រទេសនានា និងសុខមាលភាពរបស់ប្រជាពលរដ្ឋ។

## សមិទ្ធផលដែលយើងសម្រេចបានកាលពីពេលថ្មីៗនេះ

- ការរៀបចំ និងការអនុម័តលើយុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់អាងទន្លេ (BDS) ២០១៦-២០២០ ដោយប្រើប្រាស់គោលការណ៍ IWRM ផែនការយុទ្ធសាស្ត្រ ២០១៦-២០២០ ដើម្បីអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍តំបន់អាងទន្លេ ដោយគណៈកម្មការទន្លេមេគង្គ និងផែនការបណ្តោះអាសន្នសម្រាប់ប្រទេសនីមួយៗ ២០១៦-២០២០ រួមនឹងកិច្ចព្រមព្រៀងសហប្រតិបត្តិការលើគម្រោងរួមគ្នាចំនួនប្រាំ ដើម្បីឱ្យប្រទេសជាសមាជិកអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍតំបន់អាងទន្លេ សុទ្ធសឹងតែជាជោគជ័យគួរឱ្យកត់សម្គាល់ ដែលសម្រេចបាន។
- កំណែទម្រង់ធំៗត្រូវបានអនុវត្តចាប់ពីតាំងពីឆ្នាំ ២០១៦ ជាមួយនឹងការបង្កើតរចនាសម្ព័ន្ធថ្មីសម្រាប់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ ដែលផ្តោតការយកចិត្តទុកដាក់លើមុខងារស្នូលសំខាន់ៗ (ងាកចេញពីយុទ្ធសាស្ត្រផ្អែកតាមកម្មវិធី និងគម្រោង) យន្តការដាក់មូលនិធិទៅក្នុងកន្ត្រកមួយរួមគ្នា ដែលការកំណត់អាទិភាពចំណាយត្រូវបានធ្វើឡើងដោយគណៈកម្មការទន្លេមេគង្គ ដែលមានបុគ្គលិក និងប្រធានប្រតិបត្តិទាំងអស់ ជាអ្នកដែលមកពីប្រទេសតាមដងទន្លេនេះ ។
- ប្រទេសជាសមាជិកឯកភាពលើរូបមន្តចូលរួមភាគទានថ្មី ដែលនឹងត្រូវមានការផ្តល់មូលនិធិស្មើគ្នាត្រឹមឆ្នាំ ២០៣០ ដែលនេះជាសញ្ញាដ៏ធំមួយ បង្ហាញពីការប្តេជ្ញាចិត្តរបស់ប្រទេសជា

សមាជិកគណៈកម្មការទន្លេមេគង្គក្នុងការបន្តបង្កើនប្រាក់បដិភាគ និងធ្វើយ៉ាងណាឱ្យស្ថាប័ននេះមាននិរន្តរភាពដោយខ្លួនឯង នាពេលអនាគត។

- សម្រាប់រយៈពេលផែនការយុទ្ធសាស្រ្តបច្ចុប្បន្ន មូលនិធិជាង ៩០% បានទទួលពីប្រទេសជាសមាជិក និងដៃគូអភិវឌ្ឍន៍។
- នៅក្នុងឆ្នាំកន្លងទៅថ្មីៗនេះ គណៈកម្មការទន្លេមេគង្គបានពង្រឹងភាពជាដៃគូ ការចូលរួម ការប្រាស្រ័យទាក់ទង និងការផ្សព្វផ្សាយព័ត៌មានរបស់ខ្លួន។ ឧទាហរណ៍ក្នុងឆ្នាំ ២០១៧ គណៈកម្មការទន្លេមេគង្គបានរៀបចំវេទិកាជាមួយអ្នកពាក់ព័ន្ធថ្នាក់តំបន់ចំនួនប្រាំមួយ ដែលវេទិកានេះមានគោលបំណងជំរុញឱ្យមានកិច្ចពិគ្រោះយោបល់ ដោយចំហ និងដោយលក្ខណៈស្ថាបនាលើបញ្ហាសំខាន់ៗនានា ដែលបង្កផលប៉ះពាល់មកលើតំបន់អាងទន្លេមេគង្គ និងតួនាទីរបស់គណៈកម្មការទន្លេមេគង្គក្នុងការឆ្លើយតបចំពោះបញ្ហាទាំងនេះ។ គណៈកម្មការទន្លេមេគង្គ ក៏បានបង្កើនការចូលរួមសហការជាមួយសារព័ត៌មាន និងការប្រើប្រាស់បណ្តាញផ្សព្វផ្សាយសង្គម ដើម្បីបង្កើនលទ្ធភាពទទួលបានព័ត៌មាន និងចំណេះដឹង សម្រាប់សាធារណជនទូទៅផងដែរ។ គណៈកម្មការនេះ បានចុះហត្ថលេខា និងបានបញ្ចប់កិច្ចព្រមព្រៀងជាច្រើនជាមួយដៃគូនៅជុំវិញពិភពលោក។
- ក្នុងឆ្នាំ ២០១៧ គណៈកម្មការទន្លេមេគង្គបានបញ្ចប់ការសិក្សារយៈពេលប្រាំមួយឆ្នាំ ស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍទន្លេមេគង្គប្រកបដោយចីរភាព ដែលមានឈ្មោះថា ការសិក្សារបស់ក្រុមប្រឹក្សា (Council Study)។ ផលប៉ះពាល់ ហានិភ័យ និងអត្ថប្រយោជន៍នៃគម្រោងអភិវឌ្ឍន៍ក្នុងវិស័យចំនួនប្រាំមួយ រាប់បញ្ចូលទាំងគម្រោងទំនប់វារីអគ្គិសនីនៅតាមដងទន្លេមេផងដែរ បានធ្វើឱ្យមានការពិភាក្សាលើបញ្ហាសំខាន់ៗជាច្រើន ការបង្កើនការយល់ដឹង និងការបន្តអនុវត្តសកម្មភាព ដើម្បីឆ្លើយតបចំពោះបញ្ហាទាំងនេះ នៅក្នុងការងាររបស់គណៈកម្មការទន្លេមេគង្គ ក៏ដូចជាក្នុងការរៀបចំផែនការ និងការអនុវត្តរបស់ប្រទេសជាសមាជិក។
- ចាប់តាំងពីចាប់កំណើតមក គណៈកម្មការទន្លេមេគង្គបានគាំទ្រដល់ប្រទេសជាសមាជិកក្នុងការរៀបចំនូវនីតិវិធីប្រើប្រាស់ទឹកចំនួនប្រាំ៖ ក្នុងឆ្នាំ ២០០១ ក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គបានអនុម័តលើនីតិវិធីទី ១ ដែលផ្តោតលើការផ្លាស់ប្តូរ និងការចែករំលែកទិន្នន័យ និងព័ត៌មានរវាងប្រទេសទាំងបួន។ កិច្ចព្រមព្រៀងនេះ គឺជាមូលដ្ឋានសម្រាប់ប្រតិបត្តិការរបស់គណៈកម្មការទន្លេមេគង្គ ដែលផ្តល់លទ្ធភាពឱ្យស្ថាប័ននេះអាចបង្កើតនូវមូលដ្ឋានចំណេះដឹង

សម្រាប់ការគ្រប់គ្រងធនធានទឹកចម្រុះ។ ចាប់តាំងពីពេលនោះមក ក្រុមប្រឹក្សារបស់គណៈកម្មការទន្លេមេគង្គបានឯកភាពលើនីតិវិធីចំនួនបួនផ្សេងទៀត៖ នីតិវិធីចំនួនពីរសម្រាប់ ពិនិត្យតាមដានការប្រើប្រាស់ទឹក ក៏ដូចជាសម្រាប់ជូនដំណឹង និងពិគ្រោះយោបល់ ដល់សមាជិកដទៃទៀត អំពីការប្រើប្រាស់ទឹកក្នុងទន្លេមេគង្គ នីតិវិធីមួយស្តីពីការរក្សាលំហូរទឹកនៅតាមដងទន្លេមេគង្គមេ និងនីតិវិធីមួយទៀតស្តីពីស្តង់ដារគុណភាពទឹក។

- ក្នុងឆ្នាំ ២០១៧ គណៈកម្មការទន្លេមេគង្គបានសម្របសម្រួលបង្កើតឱ្យមានកិច្ចព្រមព្រៀងមួយដែលចុះហត្ថលេខាដោយប្រទេសជាសមាជិក នៅចុងដំណើរការពិគ្រោះយោបល់ជាមុនរយៈពេលប្រាំមួយខែ សម្រាប់គម្រោងវារីអគ្គិសនីប៉ាក់បេង (Pak Beng)។ ការងាររបស់គណៈកម្មការទន្លេមេគង្គក្នុងដំណើរការពិគ្រោះយោបល់ជាមុនកន្លងមកនេះ នាំឱ្យមានការកែលម្អការរៀបចំគម្រោង ដើម្បីឆ្លើយតបចំពោះបញ្ហាឆ្លងដែនសំខាន់ៗនានា។ កាលពីពេលថ្មីៗនេះ ប្រទេសជាសមាជិករបស់គណៈកម្មការទន្លេមេគង្គ បានយល់ព្រមបង្កើតនូវយន្តការពិនិត្យតាមដានបរិស្ថានរួមគ្នាលើទំនប់នៅតាមដងទន្លេមេ។
- កាលពីពេលថ្មីនៗនេះដែរ គណៈកម្មការទន្លេមេគង្គបានបញ្ចប់គោលការណ៍ណែនាំស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន។ គោលការណ៍ណែនាំនេះ ដែលគ្រោងនឹងទទួលបានការអនុម័តជាផ្លូវការនៅខែ មីនា ឆ្នាំ ២០១៨ មានគោលបំណងគាំទ្រដល់ការបង្កើនកិច្ចសហប្រតិបត្តិការបរិស្ថានឆ្លងដែន ក្នុងតំបន់អាងទន្លេមេគង្គខ្សែទឹកខាងក្រោម។
- ក្នុងកិច្ចខិតខំប្រឹងប្រែងឆ្លើយតបចំពោះផលប៉ះពាល់សំខាន់ៗ ដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ គណៈកម្មការទន្លេមេគង្គបានសម្របសម្រួលការរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្តីពីការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុក្នុងតំបន់ទន្លេមេគង្គ (MASAP)។ ឯកសារនេះត្រូវបានអនុម័តដោយប្រទេសជាសមាជិកក្នុងឆ្នាំ ២០១៧។
- យុទ្ធសាស្ត្រគ្រប់គ្រង និងអភិវឌ្ឍន៍ធនធាននេសាទក្នុងតំបន់អាងទន្លេទាំងមូល ២០១៨-២០២២ (BMFM) ដែលមានគោលបំណងធ្វើឱ្យកាន់តែប្រសើរនូវការសម្របសម្រួល ការគ្រប់គ្រងធនធាននេសាទ បានទទួលការអនុម័តពីក្រុមប្រឹក្សា MRC ក្នុងឆ្នាំ ២០១៧។
- គណៈកម្មការទន្លេមេគង្គបានពន្លឿនការសហការជាមួយប្រទេសចិន ដូចជា តាមរយៈការសហការរៀបចំសិក្ខាសាលាបច្ចេកទេសរួមគ្នាលើកទី ៣ រវាង MRC និងចិន និងការប្រកាសផ្សព្វផ្សាយពីការស្រាវជ្រាវរួមគ្នាស្តីពីផលប៉ះពាល់ជលសាស្ត្រ ដែលបង្កឡើងដោយគម្រោងវារី

អគ្គិសនី ឡានឆាង មកលើព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរនៅតំបន់ខ្សែទឹកខាងក្រោម កាលពីឆ្នាំ ២០១៧ ដោយសហការជាមួយនឹងមជ្ឈមណ្ឌលសហប្រតិបត្តិការធនធានទឹកឡានឆាង-មេគង្គ។ ក្នុងឆ្នាំ ២០១៦ MRC បានសហការជាមួយប្រទេសចិន ដើម្បីធ្វើការវាយតម្លៃរួមគ្នាលើបរិមាណទឹកបន្ថែម ដែលបញ្ចេញពីទំនប់នៅតាមទន្លេឡានឆាង (ទន្លេមេគង្គខ្សែទឹកខាងលើ) ជាការឆ្លើយតបចំពោះគ្រោះរាំងស្ងួតធ្ងន់ធ្ងរនៅតំបន់ខាងក្រោមនៃអាងទន្លេ។

- គណៈកម្មការទន្លេមេគង្គ កាលពីពេលថ្មីៗនេះបានបញ្ចប់ក្នុងការរៀបចំគោលការណ៍ណែនាំស្តីពីការកាត់បន្ថយផលបះពាល់បរិស្ថាន និងការគ្រប់គ្រងហានិភ័យនៃវារីអគ្គិសនីក្នុងទន្លេមេគង្គមេខ្សែទឹកខាងក្រោម និងតាមដៃទន្លេ ដើម្បីផ្តល់ជាការណែនាំ និងឧត្តមានុវត្តន៍សម្រាប់កាត់បន្ថយផលប៉ះពាល់អវិជ្ជមាន ដែលបង្កឡើងដោយទំនប់វារីអគ្គិសនីនៅក្នុងអាងទន្លេមេគង្គខ្សែទឹកខាងក្រោម។

## អាទិភាពរបស់យើង

ក្នុងរយៈពេលនៃផែនការយុទ្ធសាស្រ្តបច្ចុប្បន្ន ពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២០ អាទិភាពរបស់គណៈកម្មការទន្លេមេគង្គ ផ្តោតលើការបន្តការងារដ៏សំខាន់របស់ស្ថាប័ននេះ ក្នុងការជំរុញលើកកម្ពស់ការអភិវឌ្ឍធនធានទឹក និងធនធានពាក់ព័ន្ធនានាប្រកបដោយចីរភាពក្នុងតំបន់អាងទន្លេមេគង្គទាំងមូល។ ការងារសំខាន់ៗមួយចំនួន ដែលនឹងទទួលបានការយកចិត្តទុកដាក់ ត្រូវបានលើកយកមកបង្ហាញខាងក្រោម៖

១. បង្កើនការយល់ដឹង និងការប្រើប្រាស់ភស្តុតាង ដែលមានដល់អ្នករៀបចំគោលនយោបាយ និងអ្នករៀបចំផែនការ។ ឧទាហរណ៍ប្រព័ន្ធសម្រាប់ចែករំលែកទិន្នន័យ និងព័ត៌មានរបស់គណៈកម្មការទន្លេមេគង្គ មានគេហទំព័រ និងប្រព័ន្ធទិន្នន័យជាច្រើន ដែលជួយសម្រួលដល់ការផ្លោះប្តូរទិន្នន័យពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានទឹកចម្រុះរួមគ្នា។ ក្នុងឆ្នាំ ២០១៧ ផែនទីដែលមានលក្ខណៈអន្តរកម្មបង្ហាញពីការប្រែប្រួលអាកាសធាតុ គុណភាពទឹក និងការព្យាករណ៍ទឹកជំនន់ ត្រូវបានផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញដល់អ្នកប្រើប្រាស់ទាំងឡាយ ដែលមានគោលបំណងយកព័ត៌មាននេះទៅប្រើប្រាស់សម្រាប់ធ្វើការវិភាគ ឬធ្វើសេចក្តីសម្រេចចិត្ត។ នឹងមានបន្តការផ្សព្វផ្សាយលទ្ធផលរកឃើញសំខាន់ៗ ដែលបានពីការសិក្សារបស់ក្រុមប្រឹក្សា និងការសិក្សាដទៃទៀត សម្រាប់ការពិភាក្សានៅកម្រិតគោលនយោបាយនិងបច្ចេកទេស និងការពិភាក្សាទាំងឡាយដែលមានសារៈសំខាន់ សម្រាប់ការងាររបស់គណៈកម្មការទន្លេមេគង្គ។

២. គាំទ្រដល់ស្ថាប័នទទួលបន្ទុករៀបចំផែនការតាមវិស័យនៅថ្នាក់ជាតិ ដើម្បីកែលម្អការគ្រប់គ្រងបរិស្ថាន និងការអភិវឌ្ឍធនធានទឹក ការរៀបចំផែនការ និងសកម្មភាពនានាឱ្យបានល្អបំផុត ដើម្បីឱ្យមានការចែករំលែកអត្ថប្រយោជន៍ក្នុងតំបន់អាងទន្លេទាំងមូល។ ឧទាហរណ៍ គម្រោងរួមគ្នាពី NIP នឹងត្រូវពន្លឿនការអនុវត្តបន្ថែមទៀត។ យុទ្ធសាស្ត្រ និងផែនការសម្រាប់តំបន់អាងទន្លេទាំងមូលរបស់គណៈកម្មការទន្លេមេគង្គ ដូចជា ផែនការមេស្តីពីការដឹកជញ្ជូនតាមផ្លូវទឹក MASAP និង BFMS នឹងត្រូវបន្តជំរុញបន្ថែមទៀត។ BFMS គឺជាសក្ខីកម្មដែលបង្ហាញពីកម្រិតនៃការឯកភាពគ្នាជារួមក្នុងតំបន់អាងទន្លេទាំងមូល និងបង្ហាញពីភាពជាម្ចាស់លើការគ្រប់គ្រងធនធាននេសាទនៅថ្នាក់ជាតិ។ យុទ្ធសាស្ត្រនេះក៏ប្រមូលផ្តុំទិន្នន័យពីតំបន់អាងទន្លេទាំងមូលជាលើកទី ១ ដើម្បីគាំទ្រដល់ការបង្កើនប្រសិទ្ធភាព និង ការធ្វើសេចក្តីសម្រេចចិត្តជុំវិញការគ្រប់គ្រងធនធាននេសាទប្រកបដោយចីរភាពផងដែរ។

៣. ផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីការអភិវឌ្ឍ និងការគ្រប់គ្រងគម្រោង ដែលពាក់ព័ន្ធនឹងគម្រោងធនធានទឹក និងគម្រោងពាក់ព័ន្ធ និងចែករំលែកធនធានជាមួយស្ថាប័នរៀបចំផែនការ និងអនុវត្តនៅថ្នាក់ជាតិ ដើម្បីឱ្យស្ថាប័នទាំងនេះយកគោលការណ៍ណែនាំនេះទៅអនុវត្ត។ ឧទាហរណ៍ គោលការណ៍ណែនាំស្តីពីការកាត់បន្ថយផលប៉ះពាល់ការគ្រប់គ្រងហានិភ័យដែលបង្កឡើងដោយវារីអគ្គិសនី នឹងផ្តល់ការគាំទ្រដល់អ្នកអភិវឌ្ឍន៍វារីអគ្គិសនី ក្នុងអំឡុងពេលរៀបចំគម្រោង និងជំរុញឱ្យមាននិរន្តរភាពរយៈពេលវែងក្នុងតំបន់អាងទន្លេមេគង្គ។

៤. ការធានានូវប្រសិទ្ធភាព និងភាពស៊ីសង្វាក់គ្នានៃការអនុវត្តនីតិវិធីរបស់ MRC ពីសំណាក់ប្រទេសជាសមាជិក។ ការងារនេះ រួមមាន នីតិវិធីសម្រាប់ផ្តល់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង (PNPCA) ដែលផ្តល់លទ្ធភាពឱ្យប្រទេសជាសមាជិករបស់ MRC ធ្វើការពិភាក្សានិងវាយតម្លៃពីអត្ថប្រយោជន៍ និងហានិភ័យរបស់គម្រោងប្រើប្រាស់ធនធានទឹកដែលស្នើឡើងនានា ដែលអាចបង្កផលប៉ះពាល់គួរឱ្យកត់សម្គាល់មកលើទន្លេមេគង្គមេ។

៥. សម្របសម្រួលកិច្ចពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព រវាងប្រទេសជាសមាជិក និងការចូលរួមក្នុងលក្ខណៈជាយុទ្ធសាស្ត្រជាមួយដៃគូនៅថ្នាក់តំបន់ និងអ្នកពាក់ព័ន្ធនានាជុំវិញការគ្រប់គ្រងធនធានទឹកឆ្លងដែន។ ក្នុងឆ្នាំ ២០១៧ MRC បានរៀបចំនូវវេទិកាអ្នកពាក់ព័ន្ធថ្នាក់តំបន់ ដោយផ្តោតលើបញ្ហាជាច្រើន ដែលនេះជាការអនុវត្ត ដែលនឹងបន្តធ្វើនៅក្នុងឆ្នាំខាងមុខទៀត។

៦. ការពង្រឹង ការពិនិត្យតាមដាន ការព្យាករណ៍ ការវាយតម្លៃផលប៉ះពាល់ និងការផ្សព្វផ្សាយលទ្ធផលនៅក្នុងតំបន់អាងទន្លេមេគង្គទាំងមូល ដើម្បីគាំទ្រដល់ការធ្វើសេចក្តីសម្រេចចិត្តកាន់តែល្អប្រសើរជាងមុន ពីសំណាក់ប្រទេសជាសមាជិក។ ការងារនេះ រួមមាន ការកែលម្អប្រព័ន្ធពិនិត្យតាមដានបែបមជ្ឈការ និងវិមជ្ឈការ ការព្យាករណ៍ទឹកជំនន់ និងគ្រោះរាំងស្ងួត ការគ្រប់គ្រងនិងការទទួលបានទន្នន័យ និងព័ត៌មាន និងការរៀបចំរបាយការណ៍ ស្តីពីស្ថានភាពរបស់តំបន់អាងទន្លេ។

៧. បន្តដំណើរការកំណែទម្រង់ និងខិតខំបង្កើនឱ្យស្ថាប័ននេះក្លាយជាស្ថាប័នដែលមានប្រសិទ្ធភាព ប្រសិទ្ធផល និងនិរន្តរភាព ស្របទៅតាមផែនការកំណែនទម្រង់ដែលត្រូវបានដាក់ចេញ។

## មាគ៌ារបស់យើងទៅកាន់ឆ្នាំ ២០៣០

ដំណើរការវិមជ្ឈការរបស់ MRC កំពុងត្រូវបានអនុវត្តចាប់តាំងពី កិច្ចប្រជុំកំពូលលើកទី ១ ក្នុងឆ្នាំ ២០១០ មក។

ដំណើរការវិមជ្ឈការដែលនៅបន្តអនុវត្តទៀតនេះ សំដៅសម្រេចគោលបំណងចំនួនបី៖

- ធ្វើយ៉ាងណាឱ្យការងារស្នូលរបស់គណៈកម្មការទន្លេមេគង្គ ទទួលបានហិរញ្ញប្បទានទាំងស្រុងពីប្រទេសជាសមាជិកត្រឹមឆ្នាំ ២០៣០។
- ធ្វើវិមជ្ឈការការងារស្នូលមួយចំនួនទៅឱ្យប្រទេសជាសមាជិក និង
- ប្រែក្លាយលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ ទៅជាស្ថាប័នតូចជាងមុន ដោយផ្តោតតែលើមុខងារ ដែលពាក់ព័ន្ធនឹងបេសកកម្មរបស់ខ្លួនតែប៉ុណ្ណោះ។

###